ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# ព្រះរាជកំណើតនៃព្រះយេស៊ូ



និពន្ធដោយៈ Edward Hughes

ធ្វើការពន្យល់ដោយៈ M. Maillot
Alastair Paterson

កែសម្រួលដោយៈ E. Frischbutter Sarah S.

បកប្រែដោយៈ www.christian-translation.com

ផលិតដោយៈ Bible for Children
www.M1914.org

©2020 Bible for Children, Inc.
អាជ្ញាប័ណ្ណៈ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។



កាលពីយូរលង់ណាស់មកហើយ ព្រះទ្រង់
បានបញ្ជូនទេវតា ហ្កាប់ព្រីអ៊ែល ទៅជួប
នារីក្រមុំជនជាតិជូហ្វដ៏ទន់ភ្លន់ម្នាក់
ដែលមានឈ្មោះថា ម៉ារី។ គាត់បាន
ប្រាប់នាងថា “នាងនឹងមានកូន
ប្រុសម្នាក់ ហើយសូមដាក់ឈ្មោះ
គេថា យេស៊ូ។ មនុស្សម្នានឹងហៅ
គេថាជាព្រះរាជ
បុត្រានៃព្រះដ៏ខ្ពស់
បំផុត។ ទ្រង់នឹង
សោយរាជ្យជា
រៀងដរាបតទៅ។”

នារីក្រមុំបានសួរទៅវិញដោយភាពភ្ញាក់
ផ្អើលថា “តើរឿងនេះកើតបានយ៉ាង
ដូចម្ដេចទៅ បើខ្ញុំមិនដែលនៅជាមួយ
បុរសណាម្នាក់ផងនោះ។” ទេវតាបាន
ប្រាប់ទៅម៉ារីវិញថា បុត្រានោះ
នឹងយាងមកពីព្រះ។
ទ្រង់មិនចាំបាច់
ត្រូវការឪពុកជា
មនុស្សឡើយ។



បន្ទាប់មក ទេវតាក៏បានប្រាប់ទៅម៉ារីផងដែរ
ថា អេលីហ្សាប៉ិត ដែលជាបងប្អូនជីដូនមួយ
របស់នាងក៏កំពុងមានផ្ទៃពោះក្នុងវ័យចំណាស់
របស់នាងផងដែរ។ នេះ
ក៏ជាអព្ភូតហេតុដ៏អស្ចា
រ្យមួយដែរ។ មិនយូរ
ប៉ុន្មាន ម៉ារីបានទៅ
លេង អេលីហ្សាប៉ិត។
ពួកគេបានបួងសួង
លើកតម្កើងព្រះ
ជាម្ចាស់ជាមួយគ្នា។



ម៉ារីបានភ្ជាប់ពាក្យទៅបុរសម្នាក់ឈ្មោះ យ៉ូសែប។ យ៉ូសែប មិនសប្បាយចិត្តទេ ពេលដែលគាត់បានដឹងថាម៉ារីកំពុងមានកូន។ គាត់បានគិតថា ប្រហែលជាឪពុករបស់កូននេះជាបុរសផ្សេងណាម្នាក់ហើយ។



នៅក្នុងការយល់សប្តិ, ទេវតារបស់ព្រះបានប្រាប់ហូស្សែបថា កូននេះជាបុត្ររបស់ព្រះ។ ហូស្សែបត្រូវជួយម៉ារីថែទាំព្រះយេស៊ូ។



ហូស្យែបជឿជាក់ និងគោរពតាមព្រះជាម្ចាស់។ គាត់ក៏ជា
អ្នកគោរពតាមច្បាស់របស់ប្រទេសគាត់ផងដែរ។ ដោយសារ
តែច្បាប់ថ្មី គាត់និងម៉ារីបាន
ចាកចេញទៅភូមិកំណើត
របស់ពួកគាត់
ឈ្មោះ



បិតថ្លេហែម ដើម្បីបង់ពន្ធរបស់ពួកគាត់។


ម៉ារីដល់ពេលសំរាលកូន
របស់នាងហើយ។ ប៉ុន្តែហូ
ស្យែបមិនអាចរកបាន
បន្ទប់ស្នាក់នៅទីណាសោះ។
គ្រប់ផ្ទះសំណាក់
សុទ្ធតែពេញ។

នៅទីបំផុត ហូស្យែបបានរកបានក្រោលសត្វមួយ។ ទីនោះ
ហើយ ដែលជាកន្លែងព្រះឱរសយេស៊ូបានចាប់កំណើត។

មាតាទ្រង់បានដាក់ទ្រង់នៅក្នុង
ស្នូកសត្វមួយដែលជាធម្មតាគឺជា
កន្លែងសម្រាប់
ដាក់ចំណី
សត្វ។



នៅមិនឆ្ងាយពីទីនោះ មានពួកអ្នកគង្វាលដែលនៅចាំយាម
រក្សាហ្វូងចៀមរបស់ពួកគេ។ ទេវតារបស់ព្រះជាម្ចាស់បាន
លេចឡើង ហើយប្រាប់ពួកគេពីព័ត៌មាន
ដ៏អស្ចារ្យ
នេះ។




“នៅថ្ងៃនេះ មានព្រះសង្គ្រោះមួយអង្គបានប្រសូតដល់អ្នក
រាល់គ្នានៅទីក្រុង ដេវីឌគឺជាព្រះគ្រិស្ត ជាព្រះអ
ស្ចារ្យ។ អ្នកនឹងឃើញព្រះឱរសកំពុងផ្ដេក
នៅក្នុងស្នូក
សត្វមួយ។”

រំពេចនោះ ទេវតាជាច្រើនបន្ថែមទៀតបានលេចឡើងចែងចាំង បានពោលសរសើរតម្កើងព្រះជាម្ចាស់ដោយពាក្យថា “សូមថ្វាយសិរីល្អដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយ



ពួកអ្នកគង្វាលបានប្រញាប់ទៅក្រោល
សត្វ។ ក្រោយពីបានឃើញព្រះឱរសហើយ ពួក
គេបានប្រាប់ទៅគ្រប់គ្នាដែលពួកគេបានជួប
ពីអ្វីដែលទេវតាបាននិយាយអំពីព្រះយេស៊ូ។





៤០ថ្ងៃក្រោយមក ហូស្សែ
ប និងម៉ារីបាននាំព្រះ
យេស៊ូទៅវិហារនៅ ជេរូសា
ឡិម។ មានបុរសម្នាក់
ឈ្មោះ សាយម៉ិន បាន
លើកតម្កើងសរសើរដល់
ព្រះជាម្ចាស់សំរាប់ព្រះ
ឱរស ចំណែក អាណា
ដែលជាស្ត្រីវ័យចំណាស់
ម្នាក់ និងជាអ្នកបម្រើ
ដល់ព្រះផងនោះក៏បាន
អរព្រះគុណដល់ព្រះដែល
បានប្រទានព្រះបុត្រា
ទ្រង់មកស្ថាន
មនុស្សដែរ។



អ្នកទាំងពីរសុទ្ធតែដឹងថា
ព្រះយេស៊ូជាបុត្រារបស់
ព្រះ គឺជាព្រះសង្គ្រោះ
ដែលបានសន្យាថានឹង
ត្រូវយាងមក។ ហូស្យែប
បានថ្វាយសត្វស្លាប
ចំនួនពីរដល់ព្រះជាម្ចា
ស់។ នេះគឺជាដង្វាយដែល
ក្នុងក្រឹត្យវិន័យរបស់ព្រះ
បានតម្រូវសំរាប់អ្នកក្រី
ក្រដែលត្រូវថ្វាយចំពោះ
ព្រះ នៅពេលដែលពួកគេ
យកកូនទើបនឹងកើត
បង្ហាញវត្តមាន
ដល់ព្រះជាម្ចាស់។


មួយរយៈពេលក្រោយ
មក មានផ្កាយពិសេស
មួយបាននាំពួកអ្នក
ប្រាជ្ញមកពីប៉ែកខាង
កើតប្រទេសទៅ
ជេរ៉ូសាឡិម។
“ពួកលោកបានសួរថា តើបុត្រា
ដែលត្រូវប្រសូតមកធ្វើជាស្តេច
របស់សាសន៍ជូហ្វនៅទីណា?
ពួកយើងខ្ញុំចង់ថ្វាយបង្គំទ្រង់។”

ស្តេចហេរ៉ូត បានលឺពីពួក
អ្នកប្រាជ្ញទាំងនោះ។ ដោយ
មានព្រះទ័យតក់ស្លុត ទ្រង់ក៏
បានសុំអោយពួកអ្នកប្រាជ្ញ
ទាំងនោះប្រាប់ដល់ទ្រង់វិញ
ផងនៅពេលដែលពួកលោក
រកឃើញព្រះយេស៊ូ។ ទ្រង់បាន
មានបន្ទូលកុហកថា “យើង
ចង់ថ្វាយបង្គំទ្រង់ដែរ” តាម
ពិតទៅ ស្តេចហេរ៉ូតចង់
សម្លាប់ព្រះយេស៊ូ
នៅវិញទេ។



ផ្កាយបាននាំពួកអ្នកប្រាជ្ញទៅ
ដល់ចំផ្ទះដែលម៉ារី និងហូស្សែប
រស់នៅជាមួយព្រះកុមារយេស៊ូ។
ពួកលោកក៏បានលុតជង្គង់ចុះ
ថ្វាយបង្គំទ្រង់ ព្រមទាំងបាន
ថ្វាយព្រះយេស៊ូនូវជង្វាយជា
មាស និងទឹកអប់
ជាច្រើនផងដែរ។



ព្រះជាម្ចាស់បានព្រមានដល់ពួក
អ្នកប្រាជ្ញអោយត្រលប់ទៅស្រុក
របស់គេវិញជាសម្ងាត់។ ស្ដេចហេ
រ៉ូតខឹងសម្បារខ្លាំងណាស់។ ហេតុ
តែចង់បំផ្លាញព្រះយេស៊ូ ស្ដេចដ៏
អាក្រក់នេះក៏បានបញ្ជាអោយសំ
លាប់គ្រប់ក្មេងប្រុសៗទាំង
អស់នៅ
បិតថ្លេ
ហែម។





ប៉ុន្តែស្តេចហេរ៉ូតមិន
អាចបង្កគ្រោះថ្នាក់ដល់
ព្រះបុត្រារបស់ព្រះបាន
ឡើយ! ដោយទទួលបាន
ការព្រមានជាមុននៅ
ក្នុងការពន្យល់សប្តិ
ហ្វូសែ្សបបាននាំម៉ារី និង
ព្រះយេស៊ូគេចខ្លួនទៅអេ
ស៊ីបដោយសុវត្ថិភាព។

នៅពេលដែលស្ដេចហេរ៉ូតសោយទីវង្គត់ យ៉ូសែបបាននាំម៉ារី និងព្រះ



យេស៊ូត្រលប់ពីអេស៊ីបវិញ។ ពួកគេបានរស់នៅក្នុងភូមិតូចមួយឈ្មោះណាស្សារ៉េត នៅជិតសមុទ្រកាលីឡេ។

# ព្រះរាជកំណើតនៃព្រះយេស៊ូ

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់, ព្រះគុម្ពីរ,

អាចរកឃើញនៅក្នុង

ម៉ាថាយ ១-២, លូកា ១-២

“ការបើកសម្ដែងនូវព្រះបន្ទូលទ្រង់ផ្ដល់នូវពន្លឺ។”
ទំនុកតម្កើង ១១៩៖ ១៣០


មប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់
យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថា
ជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្ដីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើង
ខ្លាំងណាស់ ដល់ម្ល៉េះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រា
តែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោស
នោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅ
ស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះ
អំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់
ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឱព្រះយេស៊ូ
ទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគត
ជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូម
ទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់
ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូល
បង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់
ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាម៉ែន។

សូមអានព្រះគុម្ពីរ ហើយអធិស្ឋានទៅព្រះជារៀងរាល់ថ្ងៃ! យ៉ូហាន ៣៖១៦